www.kidworship.kr



17Page



18Page



19Page

# កាអ៊ីននិងអេបិល

- 3rd Story -

**Nar** ព្រះជាម្ចាស់បានបង្កើតអាដាមនិងអេវ៉ាជាមនុស្សដំបូង។
បន្ទាប់មក អាដាមនិងអេវ៉ាបង្កើតបានកូនប្រុស២នាក់។
កូនបងឈ្មោះថា កាអ៊ីន។ កូនប្អូនឈ្មោះថា អេបិល។
ក្មេងប្រុសទាំងពីរនាក់នេះបានធំធាត់ឡើងយ៉ាងឆាប់រហ័ស។
កាអ៊ីនបានក្លាយជាអ្នកធ្វើស្រែចំការ។
ឯប្អូនប្រុសឈ្មោះថា អេបិលបានក្លាយជាអ្នកឃ្វាលសត្វ។
អេបិលបានឲ្យចំណីអាហារល្អៗដល់ហ្វូងចៀមរបស់គាត់
និងបានការពារហ្វូងចៀមរបស់គាត់ពីសត្វសាហាវផ្សេងៗផងដែរ។

**Nar** មានថ្ងៃមួយ អេបិលបានយកចៀមដ៏ល្អមួយពីហ្វូងចៀមរបស់គាត់
មកថ្វាយដល់ព្រះជាម្ចាស់។
ចំណែក កាអ៊ីនក៏បានយកផ្លែឈើដែលបានផលមកពីដី
មកថ្វាយដល់ព្រះជាម្ចាស់ដែរ។
ប៉ុន្តែ ព្រះជាម្ចាស់ព្រមយកតែដង្វាយរបស់អេបិលប៉ុណ្ណោះ។
ព្រះជាម្ចាស់មិនពេញចិត្តនឹងកាអ៊ីននិងដង្វាយរបស់គាត់ឡើយ។
ហេតុនេះបានជា កាអ៊ីនមានចិត្តខឹងនិងស្អប់ដល់អេបិល
ដែលជាប្អូនប្រុសរបស់គាត់យ៉ាងខ្លាំង។

**Cain** ហេតុអ្វីព្រះជាម្ចាស់យកតែដង្វាយរបស់អេបិលអញ្ចឹង?
បើអេបិលមិននៅ......
នោះ ព្រះជាម្ចាស់នឹងពេញចិត្តដង្វាយរបស់ខ្ញុំ ហើយមើលទៅ......។

**Nar** ពេលនោះ កាអ៊ីនមានចិត្តខឹងទៅកាន់ព្រះជាម្ចាស់
ហើយក៏មានចិត្តច្រណែនដល់ប្អូនប្រុសរបស់គាត់ដែរ។
ក្រោយមកនៅថ្ងៃមួយ ព្រះជាម្ចាស់រកអេបិលមិនឃើញ។
ព្រះជាម្ចាស់បានសួរកាអ៊ីនថា

**God** កាអ៊ីនអើយ! តើអេបិលនៅឯណា?

**Cain** ព្រះជាម្ចាស់អើយ! ខ្ញុំមិនដឹងទេ។
តើខ្ញុំជាអ្នកចាំយាមប្អូនខ្ញុំឬ?
ខ្ញុំពិតជារវល់ជាមួយការងាររបស់ខ្ញុំណាស់។

**God** កាអ៊ីនអើយ! ម្ដេចក៏ឯងធ្វើដូច្នេះ?

**Nar** ទោះបើកាអ៊ីនដឹងថាអេបិលនៅឯណា
តែគាត់នៅតែព្យាយាមកុហកព្រះជាម្ចាស់ទៀត។
ប៉ុន្តែព្រះជាម្ចាស់បានដឹងគ្រប់យ៉ាង។

---



20Page

**Cain** អេបិល! បើគ្មានឯង......!!

**Nar** កាអ៊ីនបានយកដុំថ្មមកវាយអេបិលរហូតដល់ស្លាប់។
ទោះបីព្រះជាម្ចាស់បានដឹងអ្វីគ្រប់យ៉ាងក៏ដោយ
ក៏ព្រះជាម្ចាស់នៅតែសួរកាអ៊ីនទៀត
ប៉ុន្តែកាអ៊ីនបែរជាកុហកព្រះជាម្ចាស់ទៅវិញ។

---



21Page

**God** ឈាមរបស់ប្អូនប្រុសឯង បានស្រែកយំពីដីមកដល់យើង។
ចាប់ពីពេលនេះ នៅពេលឯងភ្ជួររាស់ដី
នោះដីនឹងលែងបង្កើតផលឲ្យឯងទៀតហើយ។
ឯងនឹងគ្មានកន្លែងរស់នៅពិតប្រាកដនៅលើផែនដីនោះទេ។

**Cain** ព្រះជាម្ចាស់អើយ!
បើព្រះអង្គដេញខ្ញុំឲ្យចេញពីទឹកដីដ៏ស្រស់ស្អាត
អោយវង្វេងនៅផែនដីនេះ
ដូច្នេះបើ មានមនុស្សណារកឃើញខ្ញុំ
នោះគេនឹងសំលាប់ខ្ញុំជាមិនខាន!

**Nar** កាអ៊ីន បានគិតថា ព្រះជាម្ចាស់នឹងបោះបង់គាត់ចោល
ហេតុនេះបានជាកាអ៊ីនមានចិត្តភ័យខ្លាចថា
នឹងមានមនុស្សមកសំលាប់គាត់ នៅពេលគាត់ វង្វេងនៅ ផែនដីនេះ។
ប៉ុន្តែទោះបីកាអ៊ីនបានធ្វើអំពើបាបទាស់នឹងព្រះជាម្ចាស់ក៏ដោយ
ក៏ព្រះជាម្ចាស់នៅតែមានចិត្តមេត្តាដល់កាអ៊ីន។
ហើយព្រះជាម្ចាស់ក៏បានសន្យាជាមួយកាអ៊ីនថា
គ្មានអ្នកណាម្នាក់រកគាត់ឃើញដើម្បីនឹងសំលាប់គាត់ឡើយ។
គួរអោយស្ដាយណាស់ ដែលកាអ៊ីនបានចាកចេញពី
ព្រះជាម្ចាស់និងបានទៅរស់នៅទិសខាងលិចនៃសួនអេដែន។